ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី ស្តីទី

ហត្ថលេខានិងត្រា

**ស ខេង**

=====

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ៨៨ សសរ

## ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យសំណល់រឹងចំនួន ២.៧៩៩.៣០០M/T នាំចូលពីប្រទេសតៃវ៉ាន់ នៅទីក្រុងព្រះសីហនុ

* * * *

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-យោងតាមអនុក្រឹត លេខ ៥៧ អនក្រ-បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមសំណើរបស់ក្រសួងបរិស្ថាន

### សំរេច

**ប្រការ១** : ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យសំណល់រឹង ចំនួន ២.៧៩៩.៣០០ M/T នាំចូលពីប្រទេសតៃវ៉ាន់ នៅទីក្រុងព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សៀម រ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | ប្រធាន |
| ២-ឯកឧត្តម | **ប្រាក់ ហម** | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច | អនុប្រធាន |
| ៣-ឯកឧត្តម | **ម៉ុល លឹម** | អគ្គាធិការរងទី១ នៃអគ្គាធិការដ្ឋានកិច្ចការ... | |

| | | |
|---|---|---|
| | នាយករដ្ឋបាលនិងនគរបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម យុន ឈុនលី | អនុប្រធាននាយកដ្ឋានសណ្ដាប់ធ្នាប់សង្គម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម ឡុញ ហ៊ាល | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | សមាជិក |

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

-ចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងស្រាវជ្រាវហេតុប៉ះពាល់បរិស្ថានជាបន្ទាន់

-ធ្វើការវាយតម្លៃអំពីហេតុប៉ះពាល់ ណែនាំផ្ដល់មូលដ្ឋានអំពីការបង្ការនិងការពារ រួចលើកឡើង ជាវិធានការជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។

ប្រការ ៣ : អភិបាលក្រុងព្រះសីហនុ ត្រូវសហប្រតិបត្តិការ និងសំរបសំរួលជាមួយគណៈកម្មការនេះបំពេញភារកិច្ចអោយបានល្អ និងប្រកបដោយប្រសិទ្ធភាព ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលក្រុងព្រះសីហនុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី ស្ដីទី

ហត្ថលេខានិងត្រា

ស ខេង

=====

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៨

**សេចក្ដីសំរេច លេខ ៤៩ សសរ**

**ស្ដីពីការបង្កើតគណៈកម្មការវេចខ្ចប់ និងទុកដាក់សំណល់រឹងឧស្សាហកម្ម**

**ចំនួន ២.៧៩៩.៣OOM/T នាំចូលពីប្រទេសតៃវ៉ាន់ នៅទីក្រុងព្រះសីហនុ**

****

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា